# រឿង ចូណា
# ជាកុមារល្អ



ឆ្នាំ ២០១០

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
: លោកស្រី យឹម ចាន់ស្រី
អ្នករៀបរៀង : លោកស្រី ហួត សេយ៉ោន
វិចិត្រករ : លោក ឯម សត្យា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អវ.សសវ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

**អំណោយ អ៊ុយនីសែហ្វ**
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10008

រោងពុម្ព : **J S R C** Printing House



បូណាជាកុមារខិតខំរៀនសូត្រណាស់។

អ្នកគ្រូតែងសរសើរបូណារាល់ថ្ងៃ។



នៅផ្ទះបូណាបានជួយធ្វើការ ឪពុកនិងម្ដាយ
សព្វគ្រប់ដូចជាដងទឹក ជញ្ជូនអុស។



ជួយស្រោចបន្លែ និង ជួយបោសសំអាតផ្ទះសំបែង។



ដោយឃើញកូនឧស្សាហ៍
ធ្វើការនិងខំរៀនសូត្រដូចនោះ
ម្ដាយបូណាបានទិញស្បែកជើង
មួយគូឱ្យជារង្វាន់ដល់បូណា។ ស្បែកជើងនោះស្អាតណាស់
បាតវាធ្វើអំពីកៅស៊ូ។



បូណាពាក់ស្បែកជើងថ្មីទៅរៀនរាល់ថ្ងៃដោយ
ប្រុងប្រយ័ត្ន ខ្លាចដាច់ខ្សែ ឬប្រឡាក់ភក់។



ថ្ងៃមួយមេឃភ្លៀងខ្លាំង នៅតាមផ្លូវ មានទឹកដក់ជាថ្លុកធំៗ។ បូណាត្រូវលោតឆ្លងថ្លុកនោះ តែភ្លាត់ស្នៀតបូណាផុងជើងចូលក្នុងភក់ នាំឱ្យប្រឡាក់ស្បែកជើងថ្មី និង ខោអាវ។ បូណាចង់យំ។



ពេលនោះមានមិត្តរួមថ្នាក់ជាច្រើនដើរមកដល់។ បូណា ឃើញក៏រាំងដៃឃាត់មិនទាន់ឱ្យមិត្តឆ្លងថ្លុក។



ហើយក៏ស្ទុះទៅយកក្តារបន្ទះមួយដុំវែង មកដាក់ធ្វើជាស្ពាន ឱ្យមិត្តទាំងអស់ឆ្លងដោយស្រួល គ្មានប្រឡាក់ជើង និងខោអាវឡើយ។



មិត្តទាំងអស់បានចាប់ដៃ ទះស្នា អរគុណ និងសរសើរដល់សេចក្ដីក្លាហាន និង ទឹកចិត្តសប្បុរសល្អរបស់បូណាជាច្រើន។

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានអប់រំកុមារតូច**

CYK

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317101